ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញបន្ថែមខ្លឹមសារក្នុងមាត្រា ១៥ ជំពូកទី ៤ នៃអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១២៩៧ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពេញបន្ថែមខ្លឹមសារក្នុងមាត្រា ១៥ ជំពូកទី៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីគោលការណ៍សមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្រប

ទ័ណ្ឌី ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យ

- ចំពោះមន្ត្រីរាជការទាំងឡាយណា ដែលបានបំពេញការងារក្នុងមុខតំណែងជាអភិបាល-រងខេត្ត ក្រុង មានរយៈពេលចាប់ពី ៥ឆ្នាំជាប់គ្នាឡើង ហើយពុំមានការផ្លាស់ប្តូរក្នុងមុខតំណែងត្រូវបានធ្វើសមាហរណកម្មផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌសក្តិខុត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

__មាត្រា២__ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

__មាត្រា៣__ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០១

ហ៊ុន សែន

__ចំលងជូន__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ - កាលប្បវត្តិ